# សេចក្តីរំឭកអំពីការអនុវត្តឯកជនភាព

*សេចក្តីរំឭកនេះពិព័ណ៌នាអំពីរបៀបដែលព័ត៌មានសុខភាពរបស់ លោកអ្នកអាចត្រូវបានប្រើប្រាស់ និង បង្ហាញ **ព្រមទាំងរបៀបដែលលោក**អ្នកអាចប្រើប្រាស់ព័ត៌មានទាំងនេះ ។ សូមពិនិត្យមើលវាឡើងវិញ ។*

## 1. ព័ត៌មានសុខភាពមានការការពារ គោលការណ៍ឯកជនភាពរបស់យើងខ្ញុំ

**លក្ខណៈទូទៅ :** ការរក្សាសុវត្ថិភាពនៃព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់លោកអ្នកគឺជាការទទួលខុសត្រូវសំខាន់ដែលត្រូវអនុវត្តន៏យ៉ាងយកចិត្តទុកដាក់ នៅមជ្ឈមណ្ឌលសេវាសុខភាពអាកប្បកិរិយា ទីក្រុង សាន ចូវគីន (SJCBHS) ។ គោលការណ៍របស់យើងខ្ញុំ គឺត្រូវធានាការសម្ងាត់ និងសុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់ អតិថិជន ស្របតាមតម្រូវការរបស់រដ្ឋសហព័ន្ធ រដ្ឋ និងទីភ្នាក់ងារ ។ យើងខ្ញុំប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដើម្បីគាំទ្រសេវាកម្ម និង ការព្យាបាលដែលយើងខ្ញុំផ្តល់ជូនលោកអ្នក ។ យើងខ្ញុំប្រើប្រាស់ និង បង្ហាញព័ត៌មាន ដោយមានការឯកភាព ឬ ការអនុញ្ញាតលាយលក្ខណ៏អក្សររបស់លោកអ្នក ឬ បើមិនដូច្នេះទេ ត្រូវមានការអនុញ្ញាត ឬ តម្រូវការពីច្បាប់ (មាត្រា 42 និង 45 នៃក្រមបញ្ញត្តិសហព័ន្ធ) ។

**មូលហេតុដែលនាំឱ្យមានការពិនិត្យមើលសេចក្តីរំឭកអំពីការអនុវត្តឯកជនភាពឡើងវិញ :** មានមូលហេតុជាច្រើនដែលនាំឱ្យមានការពិនិត្យ :

- ✓ ដើម្បីជួយលោកអ្នកអោយយល់កាន់តែច្បាស់ពីសិទ្ធិលើព័ត៌មានសុខភាពរបស់លោកអ្នក ។
- ✓ ដើម្បីជួយលោកអ្នកអោយយល់ពីការទទួលខុសត្រូវរបស់ស្ថាប័នរយើងខ្ញុំក្នុងការការពារព័ត៌មានសុខភាពរបស់លោកអ្នក ។
- ✓ ដើម្បីពន្យល់ពីសិទ្ធិបង្ហាញព័ត៌មានសុខភាពរបស់លោកអ្នក ។
- ✓ ដើម្បីពន្យល់ថាតើនៅពេលណាព័ត៌មានសុខភាពរបស់មើលសេចក្តីរំឭកអំពីឯកជនភាពឡើងវិញ ។ មូលហេតុចសំខាន់ៗមាន លោកអ្នក អាចត្រូវបានបង្ហាញ ដោយមិនមានការអនុញ្ញាតពីលោកអ្នក ។
- ✓ ដើម្បីណែនាំលោកអ្នកអំពីរបៀបធ្វើបណ្តឹងតវ៉ា ។



| លេខផ្នែក | មាតិការ | ទំព័រទី |
|---|---|---|
| 1. | ព័ត៌មានសុខភាពមានការការពារ គោលការណ៏ឯកជនភាពរបស់យើងខ្ញុំ | 1 |
| 2. | យល់ដឹងអំពីទ័ន្នន័យ/ព័ត៌មានសុខភាព អាកប្បកិរិយារបស់លោកអ្នក | 1 |
| 3. | សិទ្ធិលើព័ត៌មានសុខភាពរបស់លោកអ្នក | 1-2 |
| 4. | ការទទួលខុសត្រូវរបស់ SJCBHS | 2 |
| 5. | ការបង្ហាញដែលទាក់ទងទៅនឹងការព្យាបាល ការទូទាត់ ឬ ប្រតិបត្តិការថែទាំសុខភាព ។ | 2-3 |
| 6. | ការបង្ហាញដែលទាមទារការអនុញ្ញាតពីលោកអ្នក | 3-4 |
| 7. | ការបង្ហាញដោយមិនចាំបាច់មានការយល់ព្រម ឬ ការអនុញ្ញាតរបស់លោកអ្នក ។ | 4 |
| 8. | ការធ្វើបណ្តឹងតវ៉ាអំពីឯកជនភាព | 4 |
| 9. | និយមន័យ និង ព័ត៌មានទំនាក់ទំនង | 5 |



## 2- យល់ដឹងអំពីទិន្នន័យ/ព័ត៌មានសុខភាពអាបក្បកិរិយារបស់លោកអ្នក

**លក្ខណៈទូទៅ :**

រាល់ពេលដែលអ្នកមកកាន់មន្ទីរពេទ្យ ជួបគ្រូពេទ្យ ឬ បុគ្គលិកផ្តល់សេវាថែទាំសុខភាពដទៃទៀត ព័ត៌មានអំពីការមករបស់លោកអ្នកត្រូវបានកត់ត្រាទុក ។ ជាធម្មតាព័ត៌មានទាំងនេះមាន រោគសញ្ញា ការពិនិត្យ និង លទ្ធផលតេស្ត រោគវិនិច្ឆ័យ ការព្យាបាល និង ផែនការថែទាំ ឬ ព្យាបាលនាអនាគតកាល ។ ព័ត៌មានដែលញឹកញាប់ជាព័ត៌មានសុខភាព និង ឱសថរបស់លោកអ្នកនេះ បំពេញតួនាទីជា :

- មូលដ្ឋានសម្រាប់ធ្វើផែនការថែទាំ និងព្យាបាលរបស់លោកអ្នក ។
- របៀបទំនាក់ទំនងនៅក្នុងចំណោមអ្នកជំនាញខាងថែទាំសុខភាពជាច្រើននាក់ដែលផ្តល់ការថែទាំជូនលោកអ្នក ។
- ឯកសារច្បាប់ដែលបង្ហាញពីសេវាថែទាំដែលលោកអ្នកទទួលបាន ។
- របៀបដែលលោកអ្នក ឬ អ្នកបង់ប្រាក់ជាភាគីបី (ដូចជាក្រុមហ៊ុនធានារ៉ាប់រង) អាចផ្ទៀងផ្ទាត់ថា សេវាក្នុងវិកយប័ត្រពិតជាត្រូវបានផ្តល់ជូនប្រាកដ និង
- សម្ភារៈដែលយើងអាចប្រើសម្រាប់វាយតម្លៃ និងបន្តពង្រឹងសេវាថែទាំ និង សេវានានាទៀត ។

## 3. សិទ្ធិលើព័ត៌មានសុខភាពរបស់លោកអ្នក

ទោះបីជាឯកសារព័ត៌មានសុខភាពរបស់លោកអ្នកជាកម្មសិទ្ធិរូបវន្តរបស ស្ថាប័នផ្តល់សេវាថែទាំសុខភាព ឬ កន្លែង ដែលចងក្រងវាក៏ដោយ វានៅតែជាកម្មសិទ្ធិរបស់លោកអ្នក ។ ខាងក្រោមជាបញ្ជីនៃសិទ្ធិរបស់លោកអ្នក :

3-1 លោកអ្នកមានសិទ្ធិស្នើសុំដាក់លក្ខខណ្ឌលើការប្រើប្រាស់ និងការបង្ហាញជាក់លាក់ ចំពោះព័ត៌មានរបស់លោកអ្នក ។ លោកអ្នកអាចផ្តល់ដំណឹងមកយើងខ្ញុំពីបំណងរបស់លោកអ្នកនៅពេលអ្នកបំពេញពាក្យផ្តល់ការអនុញ្ញាត ។ **លក្ខខណ្ឌ :** ទោះជាយ៉ាងនេះក៏ដោយ យើងខ្ញុំមិនមែនត្រូវតែយល់ស្របតាមលក្ខខណ្ឌនេះទេ ។ ប្រសិនបើយើងខ្ញុំយល់ស្រប យើងខ្ញុំនឹងប្រកាន់យ៉ាងខ្ជាប់ខ្ជួន ។ ប៉ុន្តែ ប្រសិនបើលោកអ្នកមិនស្នើសុំទេ យើងនឹងផ្តល់សេចក្តីជូនដំណឹងជូនលោកអ្នកដឹងជាមុន ។

3-2 លោកអ្នកមានសិទ្ធិទទួលបានច្បាប់ថតចម្លងនៃឯកសារនៃសេចក្តីរំឭកអំពីការអនុវត្តឯកជនភាពលាយលក្ខណ៏អក្សរតាមសំណើរ ។

3-3 លោកអ្នកមានសិទ្ធិពិនិត្យ និងថតចម្លងព័ត៌មានព្យាបាលជាក់លាក់ បន្ទាប់ពីបង្ហាញសំណើរលាយលក្ខណ៏អក្សរ និង បន្ទាប់ពីបង់សមស្រួបតាមតម្លៃ ដើម្បីបំពេញថ្លៃចំណាយលើទុកដាក់ និង ទុកព័ត៌មានទាំងនោះសម្រាប់ប្រើប្រាស់ ។ **លក្ខខណ្ឌ :** យើងខ្ញុំអាចបដិសេធ ចំពោះការប្រើប្រាស់ព័ត៌មានជាក់លាក់ ប្រសិនបើអ្នកជំនាញខាងថែទាំសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជឿជាក់តាមទស្សនៈ វិជ្ជាជីវៈរបស់ពួកគេថា វានឹងផ្តល់ផលអាក្រក់ដល់លោកអ្នក ឬមនុស្សដទៃទៀត ។

3-4 អ្នកអាចស្នើសុំឱ្យមានការកែប្រែលើឯកសារព័ត៌មានសុខភាពរបស់លោកអ្នក បន្ទាប់ពីផ្តល់មូលហេតុណាមួយ និង បង្ហាញសំណើរលាយល័ក្ខអក្សរ ។ **លក្ខខណ្ឌ :** យើងខ្ញុំមិនមែនត្រូវតែផ្តល់តាមការស្នើសុំទេ ប្រសិនបើយើងខ្ញុំមិនបានកត់ត្រាព័ត៌មានទេនោះ ។ ម្យ៉ាងវិញទៀត យើងខ្ញុំនឹងមិនកែប្រែព័ត៌មានទេ ប្រសិនបើយើងខ្ញុំដឹងថា ព័ត៌មានទាំងនោះពិតជាត្រឹមត្រូវ និងពេញលេញហើយ ។ ប្រសិនបើនៅក្នុងករណីមានរបាយការណ៍ពិគ្រោះយោបល់ពីអ្នក ផ្តល់សេវាផ្សេងទៀត ខណៈពេលដែលយើងខ្ញុំមិនបានធ្វើកំណត់ហេតុទេ យើងខ្ញុំមិនអាចដឹងថា តើវាត្រឹមត្រូវ ឬ មិនត្រឹមត្រូវទ ។ ដូច្នេះ ក្នុងករណីបែបនេះ លោកអ្នក៏ត្រូវស្វែងរកការធ្វើការកែប្រែ/ការកែ តម្រូវពីភាគីដែលបានកត់ត្រាព័ត៌មានទាំងនោះ ។ ប្រសិនបើពួកគេកែប្រែ ឬ កែតម្រូវព័ត៌មានក្នុងកំណត់ហេតុនោះ យើងនឹងបញ្ចូលព័ត៌មានដែល បានកែតម្រូវនោះទៅក្នុងកំណត់ហេតុរបស់យើងខ្ញុំ ។

3-5 សិទ្ធិមួយផ្សេងទៀតគឺការទទួលបាននូវសេចក្តីអធិប្បាយអំពីការបង្ហាញព័ត៌មានសុខភាពមានការការពារ (PHI) ដែលត្រូវបានបង្ហាញ ដោយមានមូលហេតុណាផ្សេងពីការព្យាបាល ការទូទាត់បំណុល ឬ សកម្មភាពថែទាំសុខភាព ។ **លក្ខខណ្ឌ :** យើងមិនមែនត្រូវតែរក្សាសេចក្តីអធិប្បាយ អំពីការបង្ហាញដែលធ្វើឡើងមុន 4/14/03 អាចជាការរបង្ហាញដែលធ្វើឡើងសម្រាប់លោកអ្នក មន្ត្រីសហព័ន្ធសម្រាប់សន្តិសុខជាតិ ការស៊ើបអង្កេត ស្ថាប័នកែតម្រូវ ឬ ការអនុវត្តច្បាប់ដូចដែលមានការអនុញ្ញាតដោយច្បាប់ ។

3-6 លោកអ្នកអាចស្នើសុំទំនាក់ទំនងដោយសម្ងាត់ អំពីព័ត៌មានសុខភាព លោកអ្នកដោយមធ្យោបាយផ្សេងទៀត ឬ នៅទីតាំងផ្សេងទៀត (ឧទាហរណ៏ តាមរយៈទូរសារ ឬ តាមអាសយដ្ឋានផ្សេង) ។

**ស្តង់ដាចាំបាច់អប្បបរមា**

**នេះមានន័យថាដែលយើងនឹងខិតខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវ ដោយមិនប្រើប្រាស់ បង្ហាញ ឬ ស្នើសុំលើសពីព័ត៌មានសុខភាពមានការការពារ (PHI) ដែលចាំបាច់សម្រាប់អនុវត្តកិច្ចការចេតនាទេ ។**

### 4- ការទទួលខុសត្រូវរបស់ SJCBHS

នៅមជ្ឈមណ្ឌលសេវាសុខភាពអាកប្បកិរិយា ទីក្រុង សាន ចូវគីន (SJCBHS) ត្រូវ :

4-1 រក្សាឯកជនភាពនៃព័ត៌មានសុខភាពរបស់លោកអ្នក ។

4-2 ផ្តល់ជូនលោកអ្នកនូវសេចក្តីរំឭកអំពីភារកិច្ចស្របច្បាប់ និង ការអនុវត្តឯកជនភាព របស់យើងខ្ញុំ ដោយគោរពចំពោះព័ត៌មានអំពីលោកអ្នក ដែលយើងប្រមូល និង រក្សាទុក ។

4-3 គោរពតាមលក្ខខណ្ឌនៃសេចក្តីរំឭកនេះ ។

4-4 សម្រេះសម្រួលសំណើរសមហេតុសមផលរបស់លោកអ្នកក្នុងការភ្ជាប់ទំនាក់ទំនងរវាងព័ត៌មានសុខភាពរបស់លោកអ្នកជាមួយលោកអ្នក តាមមធ្យោបាយ ឬ នៅទីតាំងផ្សេងទៀត ។

4-5 បដិសេធសិទ្ធិប្រើប្រាស់ PHI របស់លោកអ្នកនៅក្នុងករណីជាក់លាក់ដូចជា អ្នកជំនាញខាងថែទាំសុខភាព ជឿជាក់តាមទស្សនៈវិជ្ជាជីវៈរបស់ពួកគេ ថា វានឹងផ្តល់ផលអាក្រក់ដល់លោកអ្នក ឬ មនុស្សដទៃទៀត ។

### 5- ការបង្ហាញដែលទាក់ទងទៅនឹងការព្យាបាល ការទូទាត់ ឬ ប្រតិបត្តិការថែទាំសុខភាព

យើងខ្ញុំប្រើប្រាស់ និង បង្ហាញព័ត៌មាន ដោយសារមូលហេតុជាច្រើន ។ សម្រាប់ការប្រើប្រាស់ និង បង្ហាញមួយចំនួន យើងខ្ញុំត្រូវការការអនុញ្ញាតជាលាយល័ក្ខអក្សររបស់លោកអ្នក ។ ជាទូទៅ យើងអាចប្រើប្រាស់ ឬ បង្ហាញព័ត៌មាន PHI នៅពេលវាត្រូវការសម្រាប់ការព្យាបាល ការទូទាត់ និង/ឬ សម្រាប់ប្រតិបត្តិ ការថែទាំសុខភាព ដោយមានការយល់ស្របជាលាយលក្ខណ៏របស់លោកអ្នក ។

នៅក្នុងផ្នែកនេះ យើងបរិយាយអំពីការប្រើប្រាស់ និង ការបង្ហាញ ដែលទាក់ទងនឹងការព្យាបាល ការូទូទាត់ប្រាក់ ឬ ប្រតិបត្តិថែទាំ សុខភាព ។

5-1 **សម្រាប់ការព្យាបាល**
យើងអាចប្រើប្រាស់/បង្ហាញ PHI របស់អ្នកទៅកាន់ គ្រូពេទ្យ គិលានុបដ្ឋាយិកា គ្រូពេទ្យ ហាត់ការ អ្នកតំណាងប្រចាំប្រ៉ូទេស អ្នកប្រឹក្សាខាងសារធាតុញៀន និង បុគ្គលិកថែទាំសុខភាពដទៃទៀតដែលផ្តល់សេវាជូនលោកអ្នក ឬ អ្នកដែលពាក់ព័ន្ធនៅក្នុងការថែទាំលោកអ្នក ។

5-2 **សម្រាប់ការបង់ប្រាក់**
យើងអាចនឹងផ្ញើវិកយប័ត្រទៅលោកអ្នក ឬ អ្នកបង់ប្រាក់ជាភាគីទីបី ដូចជាក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នក ។ ព័ត៌មានអំពី ឬ ទាក់ទងទៅ នឹងវិកយប័ត្រដែលបញ្ជាក់អំពីលោកអ្នក រោគវិនិច្ឆ័យរបស់អ្នក នីតិវិធី និង សម្ភារប្រើប្រាស់ផ្សេងៗ ។

### 5-3 **សម្រាប់ប្រតិបត្តិការថែទាំសុខភាព**

ប្រតិបត្តិការថែទាំសុខភាពរួមមានការគ្រប់គ្រងធុរកិច្ច ការវាស់វែងលទ្ធផលនៃកម្មវិធី ដំណោះស្រាយបណ្តឹងលក្ខខណ្ឌការងារផ្ទៃក្នុង និងនីតិវិធីនៃវាយតម្លៃវិជ្ជាជីវៈដូចជាពង្រឹងគុណភាព ។



### 5-4 **ដៃគូពាណិជ្ជកម្ម**

មានសេវាមួយចំនួនដែលត្រូវបានផ្តល់ជូនដោយស្ថាប័នរបស់យើងខ្ញុំ តាមរយៈកិច្ចសន្យាជាមួយនឹងដៃគូពាណិជ្ជកម្ម ។ ឧទាហរណ៍ ការធ្វើ តេស្តមន្ទីរពិសោធន៍ និង សេវាផ្តល់ជំនួយផ្នែកគ្រូពេទ្យនិងការព្យាបាល ផ្សេងៗទៀត ក្នុងករណី ចាំបាច់ ។ នៅពេល យើងខ្ញុំអាចបង្ហាញ ព័ត៌មានសុខភាពរបស់លោកអ្នកទៅកាន់ដៃគូពាណិជ្ជកម្ម ដូច្នេះហើយទើបពួកគេអាចអនុវត្តការងារ ដែលយើងខ្ញុំបានស្នើសុំអោយពួកគេធ្វើ ហើយ ចេញវិក័យប័ត្រជូនលោកអ្នក ឬ អ្នកបង់ប្រាក់ជាភាគីទីបីរបស់លោកអ្នក សម្រាប់សេវាកម្មដែលត្រូវបានផ្តល់ជូន ។ តែទោះបីយ៉ាងនេះក៏ដោយ ដើម្បីការពារព័ត៌មានសុខភាព របស់លោកអ្នក យើងខ្ញុំតម្រូវឱ្យដៃគូពាណិជកម្មថែរក្សាព័ត៌មាន របស់លោកអ្នកអោយមានសុវត្ថិភាពត្រឹមត្រូវ ។

**មូលដ្ឋានដែលអាចពិនិត្យសេចក្តីបដិសេធឡើងវិញ**

នៅក្នុងស្ថានភាពខាងក្រោម យើងខ្ញុំអាចបដិសេធសិទ្ធិប្រើប្រាស់របស់លោកអ្នក ប៉ុន្តែប្រសិនបើយើងខ្ញុំធ្វើដូច្នេះ យើងនឹងផ្តល់ជូនលោកអ្នកនូវការពិនិត្យឡើងវិញលើសេចក្តីសម្រេចចិត្តចំពោះការបដិសេធនោះ ។ ការបដិសេធអាចកើតឡើង នៅពេលអ្នកជំនាញផ្នែកថែទាំងសុខភាព ដែលមានអាជ្ញាប័ណ្ណ ឬ បានចុះបញ្ជីបានកំណត់នៅក្នុងការអនុវត្ត ការវិនិច្ឆ័យដោយវិជ្ជាជីវៈថា សិទ្ធិប្រើប្រាស់អាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពជីវិត ឬ រូបរាង្គកាយរបស់លោកអ្នកផ្ទាល់ ឬ មនុស្សដទៃទៀត :

- នៅពេលលោកអ្នកស្នើសុំសិទ្ធិប្រើប្រាស់
- នៅពេល PHI ធ្វើសេចក្តីអះអាងចំពោះមនុស្សផ្សេងទៀត (អ្នកផ្សេងក្រៅពីអ្នកផ្តល់សេវាថែទាំសុខភាព)
- នៅពេលសំណើរត្រូវបានធ្វើឡើងដោយអ្នកតំណាងផ្ទាល់ខ្លួនរបស់លោកអ្នក ។

ប្រសិនបើសំណើររបស់លោកអ្នកត្រូវបានបដិសេធ និង លោកអ្នកមិនត្រូវបាន ផ្តល់ជូននូវការពិនិត្យឡើងវិញលើសេចក្តីបដិសេធទេ ហើយលោកអ្នកចង់ចាត់វិធានការបន្ថែមទៀត សូមទំនាក់ទំនងផ្នែកកត់ត្រាព័ត៌មាននៃមន្ទីរសម្រាកព្យាបាល តាមរយៈទូរស័ព្ទលេខ (209) 468-8772 ។

លោកអ្នកអាចកដកសេចក្តីអនុញ្ញាតលាយល័ក្ខអក្សររបស់លោកអ្នកនៅពេលណាក៏បាន ។ ការដកសេចក្តីអនុញ្ញាតរបស់លោកអ្នកមានប្រសិទ្ធភាពអនុលោមទៅតាមការចេញផ្សាយព័ត៌មានដែលមានចុះហត្ថលេខា (ROI) ។

**លោកមិនអ្នកមានសិទ្ធិការប្រើប្រាស់ព័ត៌មានដូចខាងក្រោមនេះ :**

- ឯកសារនៃការព្យាបាលជម្ងឺផ្លូវចិត្ត (សូមមើលនិយមន័យ ទំព័រទី 5) ។
- ព័ត៌មានដែលបានចងក្រងនៅក្នុងការគិតទុកជាមុនដែលសមស្របក្នុង ឬ សម្រាប់ការប្រើប្រាស់នៅកិច្ចការ ឬ ដំណើរការ ស៊ីវិល ឧក្រិដ្ឋកម្ម ឬ រដ្ឋបាល ។
- ព័ត៌មានទទួលបានពីបុគ្គលណាម្នាក់ក្រៅពីអ្នកផ្តល់សេវា ដែលមានការសន្យាជាសម្ងាត់ ឬ ប្រសិនបើសិទ្ធិប្រើប្រាស់អាចបង្ហាញអត្តសញ្ញាណរបស់បុគ្គល ។

## 6- **ការបង្ហាញដែលទាមទារការអនុញ្ញាតពីលោកអ្នក**

### 6-1 **ការប្រើប្រាស់ និង ការបង្ហាញសម្រាប់គោលបំណងផ្សេងៗទាមទារអោយមានការអនុញ្ញាតពីលោកអ្នក**

ដូចបានលើកឡើងខាងលើ យើងខ្ញុំប្រើប្រាស់ និង បង្ហាញព័ត៌មាន ដោយមានមូលហេតុជាច្រើន ។ សម្រាប់ការព្យាបាល ការបង់ប្រាក់ ឬ ប្រតិបត្តិការថែទាំសុខភាព យើងខ្ញុំ*មិន*ត្រូវការការយល់ព្រម ពីលោកអ្នកជាមុនទេ ។ សម្រាប់ការប្រើប្រាស់ និង ការបង្ហាញដែលលើកឡើងនៅក្នុងផ្នែកនេះ យើងខ្ញុំ*ពិត*ជាត្រូវការការអនុញ្ញាតជាលាយល័ក្ខអក្សរពីលោកអ្នក ។

### 6-2 **ការស្រាវជ្រាវ**

ប្រសិនបើយើងត្រូវចូលរួមនៅក្នុងការស្រាវជ្រាវ យើងអាចបង្ហាញព័ត៌មានទៅកាន់អ្នកស្រាវជ្រាវ នៅពេលដែលការស្រាវជ្រាវរបស់ពួក ត្រូវបានឯកភាពដោយក្រុមប្រឹក្សាត្រួតពិនិត្យស្ថានប័នឡើងវិញ (IRB) ដែលបានពិនិត្យសំណើរសុំស្រាវជ្រាវឡើង និង បង្កើតពិធីការដើម្បីធានាពីសុវត្ថិភាព និង ឯកជនភាពនៃព័ត៌មានសុខភាពរបស់លោកអ្នក ។

### 6-3 **ទំនាក់ទំនងជាមួយនឹងគ្រួសារ**

ដោយសារគោលការណ៍រក្សាការសម្ងាត់របស់យើងខ្ញុំ ការបង្ហាញព័ត៌មានសុខភាពទៅកាន់សមាជិកគ្រួសារម្នាក់ ឬ សាច់ញាតិដទៃទៀត មិត្តភ័ក្តិជិតស្និត ឬអ្នកផ្សេងទៀតដែលលោកអ្នកស្គាល់ច្បាស់នឹងត្រូវបានផ្តល់ជូន ប្រសិនបើបុគ្គលនោះពាក់ព័ន្ធក្នុងការថែទាំរបស់លោកអ្នក ឬ ក្នុងការទូទាត់សម្រាប់សេវាថែទាំលោកអ្នក ។

6-4 **ការលើកកំពស់សុខភាព**
យើងខ្ញុំអាចទាក់ទងលោកអ្នកដើម្បីផ្តល់ការរំលឹកពីការណាត់ជួប ឬព័ត៌មានពីជម្រើសនៃការព្យាបាលសម្រាប់លោកអ្នក ឬ អត្ថប្រយោជន៏ និងសេវាផ្សេងៗទៀតដែលទាក់ទងនឹងសុខភាព ។

## 7- **ការបង្ហាញដោយមិនចាំបាច់<u>មានការយល់ព្រម ឬ ការអនុញ្ញាត</u> របស់លោកអ្នក**

7-1 **សេចក្តីជូនដំណឹង**
ក្នុងករណីបន្ទាន់ យើងខ្ញុំអាចប្រើប្រាស់ ឬ បង្ហាញព័ត៌មានដើម្បីជូនដំណឹង ឬ ជួយជូនដំណឹងដល់សមាជិកគ្រួសារ អ្នកតំណាងផ្ទាល់ខ្លួន ឬ មនុស្សផ្សេងដែលទទួលខុសត្រូវនៅទីតាំងរបស់អ្នកសម្រាប់ការថែទាំនិងស្ថានភាពទូទៅរបស់លោកអ្នក ។

7-2 **ការិយាល័យវិភាគសព**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់លោកអ្នកទៅកាន់អ្នកវិភាគសព និង ប្រធានរៀបចំពិធីបុណ្យសព ទៅតាមច្បាប់អនុវត្ត ដើម្បីបំពេញភារកិច្ចរបស់ពួកគេ។

7-3 **រដ្ឋបាលចំណីអាហារ និង ឱសថ (FDA)**
យើងអាចបង្ហាញ FDA នូវព័ត៌មានសុខភាពដែលទាក់ទងទៅនឹងប្រតិកម្មអាក្រក់ ដោយមានអន្តរកម្មសម្របសម្រួល ដើម្បីធានាបានសុវត្ថិភាព ។

7-4 **សំណងសម្រាប់បុគ្គលិក**
យើងអាចបង្ហាញព័តមានសុខភាពទៅកាន់ផ្នែកមានសិទ្ធិដែលចាំបាច់ក្នុងការអនុវត្តតាមច្បាប់ទាក់ទងទៅនឹងសំណងបុគ្គលិក ។

7-5 **សេវាការពារមនុស្សពេញវ័យ ឬ កុមារ**
យើងអាចរាយការណ៏អំពីព័ត៌មានសុខភាពទៅកាន់ភ្នាក់ងារដែលសម ស្របនៅក្នុងមានការរំលោភបំពាន/ការមិនយកចិត្តទុកចំពោះមនុស្សពេញវ័យ ឬ កុមារ ។

7-6 **សុខភាពសាធារណៈ**
ដោយសារតែតម្រូវដោយច្បាប់ យើងខ្ញុំអាចបង្ហាញព័ត៌មានសុខភាពរបស់លោកអ្នកទៅកាន់អាជ្ញាធរសុខភាពសាធារណៈ ឬ អាជ្ញាធរស្របច្បាប់ដែលទទួលបន្ទុកការពារ ឬ គ្រប់គ្រងជម្ងឺ ការរងរបួស ឬ ពិការភាព ។

7-7 **សុខភាពកែតម្រូវ**
ប្រសិនបើអ្នកជាមនុស្សនៅជាមួយនៃគ្រឹះស្ថានកែតម្រូវ យើងខ្ញុំអាចបង្ហាញគ្រឹះស្ថាន (ភ្នាក់ងារនៃគ្រឹះស្ថាន) នូវព័ត៌មានសុខភាពដែលចាំបាច់សម្រាប់សុខភាពរបស់លោកអ្នក និង សុខភាព និង សុវត្ថិភាពរបស់មនុស្សទូទៅ ។

7-8 **ការអនុវត្តច្បាប់**
យើងអាចបង្ហាញព័ត៌មានសុខភាពក្នុងគោលបំណងអនុវត្តច្បាប់ ដែលតម្រូវដោយច្បាប់ ឬ ឆ្លើយតបទៅនឹងដីកាមានសុពលភាព និង/ឬ សេចក្តីបង្គាប់តុលាការ ។

7-9 **ភ្នាក់ងារតាមដានសុខភាព**
ច្បាប់សហព័ន្ធតម្រូវឱ្យមានការបង្ហាញព័ត៌មានសុខភាពរបស់លោកអ្នក ទៅកាន់ភ្នាក់ងារតាមដានសុខភាពសមស្របណាមួយ។

## 8- **ការធ្វើបណ្តឹងតវ៉ាអំពីឯកជនភាព**

8-1 **គ្មានការសងសឹក**
សំខាន់ លោកអ្នកត្រូវអនុញ្ញាតអោយមនុស្សនៅកន្លែងដែលលោកអ្នកទទួលបានសេវាដឹងថា បើសិនជាលោកអ្នកមិនសប្បាយចិត្តជាមួយនឹងវិធីដែលគេ ប្រើប្រាស់ បង្ហាញ ឬ រក្សាព័ត៌មានសុខភាពរបស់លោកអ្នក អ្នកតែងតែមានសិទ្ធិធ្វើបណ្តឹងតវ៉ា ។ មិនមានការសងសឹក ចំពោះការធ្វើបណ្តឹងតវ៉ាអំពីឯកជនភាពទេ ។

8-2 **តើខ្ញុំធ្វើបណ្តឹងតវ៉ាអំពីឯកជនភាព ដោយរបៀបណា ?**
អ្នកធ្វើបណ្តឹងតវ៉ាក្នុងនាមខ្លួនឯង ។ ប្រសិនបើអ្នកជឿជាក់ថា សិទ្ធិឯកជនភាពរបស់លោកអ្នកត្រូវបានគេរំលោភបំពាន អ្នកអាចទាក់ទងអ្នកគ្រប់គ្រងនៅទីតាំង ដែលអ្នកទទួលសេវាកម្ម និង អ្នកអាចដោះស្រាយបញ្ហាបានលឿន និង សាមញ្ញបាន។

8-3 **តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនពេញចិត្ត ?**
អាចស្នើសុំឱ្យបុគ្គលផ្សេងជួយអ្នក ។ យើងខ្ញុំដឹងថា ជួនកាលអ្នកមិន យល់ស្របជាមួយនឹងដំណោះស្រាយលើដំបូងដែលត្រូវបានផ្តល់ជូន ។ យើងខ្ញុំក៏ដឹងដែរថា លោកអ្នកមិនអាចមានអារម្មណ៏ស្រួលខ្លួន ដោយបានប្រាប់អំពីបណ្តឹងតវ៉ារបស់លោកអ្នកទៅកាន់មនុស្ស ឬ នៅកន្លែងដែលអ្នកចង់ធ្វើបណ្តឹងតវ៉ា ។ លោកអ្នកអាចចាប់ ផ្តើមដំណើរការបណ្តឹងតវ៉ាទំនាក់ទំនងជាមួយនឹងមន្ត្រីឯកជនភាព តាមរយៈទូរស័ព្ទលេខ (209) 468-8859 ។ លោកអ្នកក៏មាន ជម្រើសក្នុងការធ្វើបណ្តឹងតវ៉ារបស់លោកអ្នក ជាមួយនឹង លេខាផ្នែកសេវាសុខភាព និងមនុស្សជាតិផងដែរ ។

8-4 **តើមន្ត្រីឯកជនភាពជាអ្វី ?**
បណ្តឹងតវ៉ាឯកជនភាពត្រូវបានដោះស្រាយតាមមធ្យោបាយពិសេសមួយ ។ មន្ត្រីឯកជនភាពជាបុគ្គលដែលត្រូវបានចាត់តាំងដោយនាយកផ្នែកសុខភាពអាកប្បកិរិយា ដើម្បីពិនិត្យមើល បញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធិឯកជនភាព ដែលត្រូវបានបង្ហាញនៅសេចក្តីរំឭកអំពីការអនុវត្តឯកជនភាពនេះ ។ ការស៊ើបអង្កេតលើបណ្តឹងតវ៉ារបស់លោកអ្នកនឹងត្រូវបានអនុវត្តជាមួយនឹងឯកជនភាពរបស់លោកអ្នកដែលមាននៅក្នុងចិត្ត ។

9- **និយមន័យ**

**ព័ត៌មានសុខភាពមានការការពារ (PHI)**
នៅពេលយើងប្រើប្រាស់ពាក្យនេះ យើងខ្ញុំសំដៅទៅលើ "ព័ត៌មានអតិថិជនទាំងអស់ដែលត្រូវបានស្គាល់អត្តសញ្ញាណជាលក្ខណៈបុគ្គល" ដែលត្រូវបានបង្កើតដោយ SJCBHS ឬ ទទួលដោយ SJCBHS ពីប្រភពផ្សេងៗទៀត ។

**កំណត់សម្គាល់អំពីការព្យាបាលជម្ងឺផ្លូវចិត្ត**
បទបញ្ញត្តិកំណត់ពីកំណត់សម្គាល់បែបនេះថា កំណត់សម្គាល់ដែលត្រូវបានកត់ត្រាដោយ អ្នកផ្តល់សេវាថែទាំសុខភាព ដែលជាអ្នកមានជមនាញផ្នែកសុខភាពផ្លូវចិត្ត ឬ ជាការរៀបចំឯកសារវិជ្ជាជីវៈស្តីពីការរំលោភបំពានពីសារធាតុជាតិផ្សេងៗ ឬ ជាការវិភាគលើកិច្ចសន្ទនានៅក្នុងពេលប្រឹក្សាយោបល់ជាលក្ខណៈឯកជន ។ និយមន័យនេះបូករួមទាំងការកំណត់សម្គាល់អំពីការព្យាបាលជម្ងឺផ្លូវចិត្តរបស់អ្នកប្រឹក្សាយោបល់ និង ដៃគូពាណិជ្ជកម្ម ។

**ការអនុញ្ញាត**
នៅពេលយើងពិភាក្សាអំពីការអនុញ្ញាត មានន័យថា លោកអ្នកត្រូវផ្តល់ការអនុញ្ញាតជាលាយល័ក្ខអក្សរ សម្រាប់យើងខ្ញុំ ដើម្បីប្រើប្រាស់ ឬ បង្ហាញ PHI របស់លោកអ្នកក្នុងគោលបំណងផ្សេងៗ ។ ឧទាហរណ៍ យើងនឹងស្នើសុំការអនុញ្ញាតរបស់លោកអ្នក ដើម្បីសុំព័ត៌មានពី ឬ ផ្តល់នូវព័ត៌មាន ទៅកាន់អ្នកផ្តល់សេវាខាងក្រៅ ។

**"ការយល់ស្រប ឬ មិនយល់ស្រប"**
នេះមានន័យថាយើងផ្តល់អោយអ្នកនូវឱកាសជាមុន ដើម្បីយល់ស្រប ឬ ជំទាស់នឹងការប្រើប្រាស់ ឬ បង្ហាញជាក់លាក់នូវ PHI របស់លោកអ្នក ។ វាអាចធ្វើដោយផ្ទាល់មាត់ ឬ ដោយលាយលក្ខណ៍អក្សរ ។

**បណ្តឹងតវ៉ាឯកជនភាព**
ការអនុញ្ញាតអោយនរណាម្នាក់ដឹងថា លោកអ្នកមិនយល់ស្រប ឬ មិនសប្បាយចិត្តអំពី និង សកម្មភាពដែលទាក់ទងទៅនឹងព័ត៌មានសុខភាពឯកជនរបស់លោកអ្នក និង សិទ្ធិឯកជនភាពរបស់លោកអ្នក ។

សរុបមក សេចក្តីរំឭកអំពីការអនុវត្តឯកជនភាពនេះ មានគោលបំណងច្រើន ។ គោលបំណងសំខាន់ៗរួមមាន :

- ជួយលោកអ្នកឱ្យយល់កាន់តែច្បាស់ថាតើ **នរណា អ្វី ពេលណា** នឹង **ហេតុអ្វី** អាចប្រើប្រាស់ព័ត៌មានរបស់លោកអ្នកបាន ។
- ដើម្បីជួយអោយលោកអ្នកធ្វើការសម្រេចចិត្ត ដោយមានព័ត៌មានកាន់តែច្រើន នៅពេលអនុញ្ញាតមានការបង្ហាញព័ត៌មាន ទៅកាន់បុគ្គលផ្សេងទៀត ។
- ដើម្បីជូនដំណឹងដល់លោកអ្នក ក្នុងកាលៈទេសៈដែលយើងនឹងមិនយល់ស្របជាមួយនឹងសំណើរបស់លោកអ្នក ។
- ដើម្បីជម្រាបជូនលោកអ្នកអំពីសិទ្ធិរបស់លោកអ្នកក្នុងការប្រាប់យើងខ្ញុំមិនឱ្យបង្ហាញក្នុងករណីមួយចំនួនដែលត្រូវបានបង្ហាញនៅក្នុងសេចក្តីរំឭកនេះ ។

**យើងរក្សាសទ្ធេការផ្លាសប្តូរការអនុវត្ត នង ធ្លេបទបញ្ញត្តថ្មីដែលមានប្រសិទ្ធិភាពសម្រាប់ព័ត៌មានសុខភាពទាំងអស់ដែលយើងខ្ញុំរក្សា ។ ប្រសិនបើការអនុវត្តព័ត៌មានរបស់យើងខ្ញុំមានផ្លាស់ប្តូរ យើងនឹងផ្ញើសេចក្តីជូនដំណឹងអំពីការកែប្រែទៅកាន់អាសយដ្ឋាន ដែលលោកអ្នកបានផ្តល់អោយយើងខ្ញុំ ។ យើងនឹងមិនប្រើប្រាស់ ឬ បង្ហាញព័ត៌មានសុខភាពរបស់ លោកអ្នកដោយគ្មានការអនុញ្ញាតរបស់លោកអ្នកឡើយ លើកតែដូចដែលបានបរិយាយនៅក្នុងសេចក្តីរំឭកនេះ ។**

សម្រាប់ព័ត៌មានផ្សេងៗទាក់ទងនឹងសេចក្តីរំឭកអំពីឯកជនភាព ឬ ព័ត៌មានអំពីការសម្រាកព្យាបាលរបស់លោកអ្នក លោកអ្នកអាចទំនាក់ទំនងយើងខ្ញុំជាលាយលក្ខណ៍អក្សរ តាមទូរស័ព្ទ ទូរសារ ឬ អ៊ីមែល ទៅកាន់ :

នៅមជ្ឈមណ្ឌលសេវាសុខភាពអាកប្បកិរិយា ទីក្រុង សាន ចូវគីន
លេខ 1212 N. ផ្លូវ កាលីហ្វ័រញ៉ា ស្តុកតុន CA 95202
លេខទូរស័ព្ទ : (209) 468-8700 or (888) 468-9370
លេខទូរសារ : (209) 468-8026
អ៊ីមែល : cpo@sjcbhs.org
លោកអ្នកអាចទូរស័ព្ទមកផ្ទាល់ :
មន្ត្រីឯកជនភាពរបស់យើងខ្ញុំ : (209) 468-8859
ផ្នែកកត់ត្រាព័ត៌មាននៃមន្ទីរសម្រាកព្យាបាល :
(209) 468-8772

លោកអ្នកក៏មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ក្នុងរយៈពេល 180 ថ្ងៃ គិតពីថ្ងៃដែលលោកអ្នករកឃើញបញ្ហាដែលត្រូវតវ៉ា ជាមួយនឹង :
រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង សេវាមនុស្សជាតិ សហរដ្ឋអាមេរិក
ការិយាល័យសិទ្ធិពលរដ្ឋ ដោយផ្ញើជូន ប្រធានប្រចាំតំបន់
តាមអាសយដ្ឋាន :
លេខ **50** អង្គការសហប្រជាជាតិ ផ្លាសា បន្ទប់លេខ **322**
សានហ្វ្រានស៊ីស្កូ **CA 91402**

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទមក :
***(800) 368-1019 or (866) 672-7748,***
***TTY: (866) 788-4989***

➡ សូមយល់ដឹងអំពីសិទ្ធិឯកជនភាពរបស់លោកអ្នក ។
លោកអ្នកប្រាកដជាមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា
សម្រាប់ឯកជនភាព ។